# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**KINGDOM OF CAMBODIA**

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

**Ministry of Commerce**

No. ០៧០ MoC / M 2002

ភ្នំពេញ, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពីការរឹបអូសប្រាក់កក់ពីក្រុមហ៊ុនដែលមិនបាន ទទួលយកកូតាដេញថ្លៃសំរាប់នាំចេញទៅកាន់សហរដ្ឋអាមេរិក ដែលបានដាក់អោយដេញថ្លៃ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០២

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃ ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសរបស់ក្រសួងពាណិជ្ជកម្ម លេខ ០១៣ MOC/M 2002 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០២ ស្តីពីការដាក់អោយដេញថ្លៃលើកូតាសំលៀកបំពាក់ ដែលត្រូវនាំចេញទៅសហរដ្ឋអាមេរិក សំរាប់ប្រើប្រាស់ក្នុងឆ្នាំ ២០០២
- បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១ :** រឹបអូសប្រាក់កក់ ចំនួន 10% នៃតម្លៃដេញថ្លៃសរុបរបស់ក្រុមហ៊ុន Cambotex HK Co Ltd លើកូតាប្រភេទ ៦៣៨/៦៣៩ ចំនួន ១០,០០០ ឡូតិ៍ តាមតំលៃ ១.៦០ ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយឡូតិ៍ ត្រូវជា ១.៦០០ ដុល្លារសហរដ្ឋអាមេរិក (មួយពាន់ប្រាំមួយរយដុល្លា) ដោយក្រុមហ៊ុននេះ មិនបានបង់ប្រាក់ឱ្យបានទាន់ពេលវេលាតាមកាលកំណត់ ដោយមូលហេតុបោះបង់ចោលកូតាដែលដេញថ្លៃបាន ដូចមានចែងក្នុងប្រការ១១ នៃប្រកាសរបស់ក្រសួងពាណិជ្ជកម្ម លេខ ០១៣ MOC/M 2002 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០២ ស្តីពីការដាក់អោយដេញថ្លៃកូតាសំលៀកបំពាក់ ដែលត្រូវនាំចេញទៅសហរដ្ឋអាមេរិក សំរាប់ប្រើប្រាស់ ក្នុងឆ្នាំ ២០០២ ។

រីឯបរិមាណកូតាដែលក្រុមហ៊ុនដេញថ្លៃបាននោះ ត្រូវបង្វិលមកក្រសួងពាណិជ្ជកម្មវិញ ដើម្បីទុកសំរាប់ដេញថ្លៃលើកក្រោយទៀត ។

**ប្រការ ២ :** ក្រសួងពាណិជ្ជកម្ម រក្សាសិទ្ធិមិនអនុញ្ញាតអោយក្រុមហ៊ុន Cambotex HK Co Ltd ចូលរួមដេញថ្លៃកូតាលើកក្រោយទៀតឡើយ ។

**ប្រការ ៣ :** នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស សមាជិកគណកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ ប្រធានក្រុមហ៊ុន Cambotex HK Co Ltd ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចម្លងជូន:**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- ឯកសារ-កាលប្បវត្តិ



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288